ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មេសា ២០០៤ / April 2004

បណ្ឌិត កង ចន្ទតារ័ត្ន / **Dr. Kang Chandararot**
លោកស្រី ប៉ុន ដូរីណា / **Ms. Pon Dorina**
លោក តុង គីមស៊ុន / **Mr. Tong Kim Sun**
កញ្ញា អ៊ុច ចន្ទតារានី / **Ms. Ouch Chandarany**

ភ្នំពេញ កម្ពុជា
**Phnom Penh, Cambodia**

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី៤ ២00៣, CDC អនុម័តគំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់តំលៃ ៦២,១លានដុល្លារ ឬ ៣៤,៦%តិចជាងត្រីមាសទី៣ ។ តួលេខនេះឆ្លុះបញ្ចាំងពីការថយចុះវិនិយោគក្នុងវិស័យឧស្សាហកម្ម (ជាពិសេសខាងកាត់ដេរ) ដែលចុះពី ៨៩លានដុល្លារ ដល់ ២៩,៦លានដុល្លារ និងដែលបានកាត់កងជាមួយកំណើនពី ៤,៨លានដុល្លារ ដល់ ៣២,៦លានដុល្លារនៃវិនិយោគក្នុងវិស័យសេវា ។

In the fourth quarter 2003, fixed assets approved by the CDC amounted to US$ 62.1 million, 34.6% less than in the third quarter. This mainly reflects falling investments in the industrial sector, especially in garments, which dropped to US$ 29.6 million from US$89 million. This offset growing investment in the service sector, reaching US$ 32.6 million in the fourth quarter, up from US$ 4.8 million in the third quarter.

**Fixed Assets by Sectors**
(Approval figure - in million US dollars)




*Including expansion project*
Source: Council for the Development of Cambodia

តាមពតិមានក្រសួងទេសចរណ៍ នៅខែមករា ២00៤ ភ្ញៀវកម្ពុជាទៅសៀមរាបកើនដល់ ៥៧.0៦៦នាក់ដែលជាកំរិតខ្ពស់បំផុតមកទល់សព្វថ្ងៃ ។ ធៀបនឹងខែដូចគ្នាឆ្នាំមុន ភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក កើនយ៉ាងខ្លាំងពីប្រហែល ៦.000នាក់ ដល់ជាង ៥៦.000នាក់ ។ ឯភ្ញៀវមកតាមផ្លូវអាកាសថយចុះពី ៧៤៦នាក់ ដល់ ៦៣0នាក់ ។ ភ្ញៀវចូលតាមផ្លូវគោកមកពីភ្នំពេញកើនយ៉ាងលឿនពី ២.៧៦៨នាក់ ដល់ ៣៦.៤៨៣នាក់ ដោយសារផ្លូវល្អ ។

According to the Ministry of Tourism, the number of Cambodian visitors to Siem Reap reached 57,066 persons in January 2004, the highest level to date. Compared to the same month last year, there was a sharp increase in arrivals by land and boat from just around 6000 to over 56,000 persons. Arrivals by air declined to 630 persons - from 746 persons. The number of visitors using the land route from Phnom Penh also rose quickly to 36,483 persons from 2,768 persons, as a result of a much improved road system.

**Cambodian Visitor to Siem Reap**
(in thousands persons)




Source: Ministry of Tourism

ភ្ញៀវបរទេសចូលតាមអាកាសយានដ្ឋានសៀមរាប បន្តកើន៨ខែជាប់គ្នាដល់ ៣៣.៦៨៩នាក់នៅខែមករា ២00៤ ដែលច្រើនជាងភ្ញៀវចូលតាមអាកាសយានដ្ឋានភ្នំពេញ (២៧.៧៦៧នាក់) ជាលើកទី១ ។ ភ្ញៀវមកតាមជើងហោះហើរផ្ទាល់ពីវៀតណាមមានចំណែកធំបំផុត (១៧.៤៣៦នាក់ ឬ ៥២% នៃភ្ញៀវអន្តរជាតិទាំងអស់ ឬ ៦២,៦%ខ្ពស់ជាងកាលពី១ឆ្នាំមុន) ។

In January 2004, the number of foreign visitors to Siem Reap airport continued to increase for the eighth consecutive month, reaching 33,689 persons which exceeded the number of foreign visitors to Phnom Penh airport (27,767 persons) for the first time ever. Passengers arriving on direct flights from Vietnam made the largest contribution (17,436 persons or 52% of total international arrivals). This figure is 62.6% higher than to one year ago.

**Number of Arrivals on Int'l Flights**
(in thousands persons)




Source: Ministry of Tourism

# ថ្លៃទំនិញ និង អត្រាការប្រាក់

# Prices and Interest Rates Developments

សាំងនៅភ្នំពេញបន្តឡើងថ្លៃ៣ខែជាប់គ្នាដល់ ២.៦៥០រៀល/លីត្រ នៅខែមីនា ២០០៤ ធៀបនឹង ២.៥៥០រៀល/លីត្រនៅខែមុន ។ ប៉ុន្តែថ្លៃសាំងនៅបាត់ដំបង និង សៀមរាប នៅនឹងត្រឹម ២.៥០០រៀល/លីត្រ និង ២.៦០០រៀល/លីត្រ ។ ធៀបនឹងកាលពី១ឆ្នាំមុន សាំងឡើងថ្លៃ ៦%នៅភ្នំពេញ, ២%នៅបាត់ដំបង, និង ៤%នៅសៀមរាប ។

In March 2004, the price of gasoline in Phnom Penh continued to rise for the third consecutive month to 2,650 riels/litre, up from 2,550 riels/litre in the previous month. However, the price of gasoline in Battambang and Siem Reap remained stable at 2,500 riels/litre and 2,600 riels/litre, respectively. Compared to one year ago, the price of gasoline rose by 6% in Phnom Penh, by 2% in Battambang, and by 4% in Siem Reap.

**Prices of Gasoline in Battambang, Siem Reap and Phnom Penh (riel/litre)**




Source: CDRI and National Institute of Statistics

ដូចការរំពឹងទុក ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញបន្តកើនឡើង ០,២%នៅខែកុម្ភៈ២០០៤ ដែលជំរុញលឿនដោយសារកំនើនថ្លៃដឹកជញ្ជូន(០,៨%) ប៉ុន្តែដែលត្រូវបានកាត់កងដោយសារការចុះថ្លៃសំលៀកបំពាក់ និងស្បែកជើង (០,១%) ។ ម្ហូបអាហារឡើងថ្លៃលឿនជាងមុនដល់០,២% ក្នុងនេះសាច់គោស្ទុះឡើង ៨,១% រីឯស៊ុតចុះថ្លៃ ៥% ដោយសារការខ្លាចជំងឺផ្តាសាយបក្សី ។

As expected, consumer prices in Phnom Penh continued to rise, by 0.2% in February 2004. The price increase was accelerated by rising price of transportation and communication (0.8%), but partly offset by declining price of clothing and footwear (0.1%). Food prices increased a little faster by 0.2%, compared with 0.1% in January. Amongst food items, the price of beef jumped by 8.1%, whereas the price of eggs dropped by 5%, mainly due to the bird flu scare.

**Consumer Price Index**

(July-December 2000 = 100)




*Note: The latest data available is for February 2004.*
Source: National Institute of Statistics

នៅខែកុម្ភៈ ២០០៤ កម្មករសំណង់មានជំនាញរកចំណូលបាន ១៣.៨០០៛ (៣,៤ដុល្លារ) /ថ្ងៃ គឺបន្តនាំមុខគេក្នុងចំណោមពលករងាយរងគ្រោះដែលវិបសអ ធ្វើអង្កេត ។ ចំនួលចារិករបស់ពួកគេកើន ១០%ធៀបនឹងកាលពី១ឆ្នាំមុន ។ ផ្ទុយទៅវិញកម្មករកាត់ដេរថយចុះចំណូលប្រចាំថ្ងៃ ៣% ដោយសារការថយចុះការងារម៉ោងបន្ថែម ។

In February 2004, skilled construction workers earned 13,800 riels (3.4 US$) per day, continuing their lead amongst vulnerable workers surveyed by CDRI. Compared to one year ago, their earnings increased by 10% in nominal terms. In contrast, garment workers experienced a drop in income levels, with daily earnings falling by 3 %, mainly as a consequence of declining over-time work.

**Average daily income and food spending (in US$) of vulnerable workers in Phnom Penh**

(February 2004)




Source: CDRI

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ
# Exchange Rates and Monetary Developments

ក្រោយឡើងថ្លៃ៦ខែជាប់គ្នា នៅខែមីនា ២004 ប្រាក់រៀលកម្ពុជាចុះថ្លៃបន្តិចវិញត្រឹម 0,៣% ទល់នឹងដុល្លារ បើធៀបនឹងខែមុន ។ រឿងនេះប្រហែលឆ្លុះបញ្ចាំងពីការឡើងថ្លៃដុល្លារក្នុងទីផ្សារអន្តរជាតិក្នុងប៉ុន្មានសប្តាហ៍ថ្មីៗ ។ បើគិតជាបំរែបំរួលប្រចាំឆ្នាំ ប្រាក់រៀលចុះថ្លៃ ១,១% ទល់នឹងដុល្លារ ។

After strengthening for the sixth consecutive month, the Cambodian riel depreciated slightly (by 0.3 %) against the US dollar in March 2004 compared to the preceding month. This probably reflects the gains that the dollar has made in international currency markets in recent weeks. On an annual basis, the riel depreciated by 1.1% against the dollar.

**Cambodian Riels per US Dollar**
(market and official rates)




Source: National Bank of Cambodia and CDRI

នៅខែមីនា ២004 ប្រាក់រៀល ឡើងថ្លៃបន្តិចទល់នឹងប្រាក់បាត ដោយប្តូរបាន ១0១,៥រៀល/បាត ឬឡើងថ្លៃ 0,៥% ធៀបនឹងខែកុម្ភៈ ។ រឿងនេះបណ្តាលជាសំខាន់ដោយប្រាក់បាតបានចុះថ្លៃខ្លាំងជាងប្រាក់រៀល ទល់នឹងប្រាក់ដុល្លារ ។ នៅខែមីនានេះដែរ ប្រាក់រៀលនៅនឹងទល់នឹងប្រាក់ដុង ដោយប្តូរបាន ២៤,៥រៀល/១00ដុង ។

In March 2004, the Cambodian riel showed some strength against the Thai baht - trading at 101.5 riels/baht, i.e. an appreciation of 0.5% compared to February. This was mainly due to a sharper depreciation of the baht against the dollar compared to the riel. In the meantime, the value of the riel against the dong remained unchanged at 24.5 riels/100 dongs in March.

**Cambodian Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI and the Economist

គិតពីមួយខែទៅមួយខែ រូបិយវត្ថុទូទៅ (M2) កើនកាន់តែលឿនដល់ ៣.៤៧៥ពាន់លានរៀល (៨៧១លានដុល្លារ) ឬកើន ៤,៧%នៅខែមករា (៣,៥%កាលពីខែមុន) ។ តួលេខនេះឆ្លុះបញ្ចាំងជាសំខាន់នូវកំណើនប្រាក់បញ្ញើជារូបិយវត្ថុបរទេស (៥,៣%) ដល់ ៦0៩លានដុល្លារ និងការចុះថ្លៃ 0,៣%នៃប្រាក់រៀល ហើយកត្តាទាំងពីរនេះបានប៉ះប៉ូវលើសក៏រិតវិញនូវនយោបាយរូបិយវត្ថុបង្រួមចុះដែល ធនាគារជាតិនៃកម្ពុជា បានអនុវត្ត ។

On a month to month basis, liquidity through the banking system rose faster by 4.7% to 3,475 billion riels (US$ 871 million) in January 2004, compared with 3.5% in the preceding month. The faster liquidity expansion basically reflects an increase in foreign currency deposits (by 5.3%) rising to US$ 609 million, and a depreciation of the riel (by 0.3%) – both of which overcompensated for the effect of a contractionary monetary policy pursued by the NBC.

**Liquidity through the Banking System**
(in billion riels)




*Note: The latest data available is for January 2004.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

តាមទីចាត់ការគយ ការនាំចេញរបស់កម្ពុជានៅត្រីមាសទី៤ ២00៣ ចុះដល់ ៤៧៥,៨លានដុល្លារ ឬថយចុះ ៣,៤% ធៀបនឹងត្រីមាសទី៣ ហើយកត្តាសំខាន់គឺការថយចុះ ១,៧% នៃសំលៀកបំពាក់នាំចេញទៅ US ។ ប៉ុន្តែ US នៅតែជាទីផ្សារចំបងសំរាប់ការនាំចេញរបស់កម្ពុជា (៦២,៨%), បន្ទាប់មកគឺ EU (២៦,៣%) និង អាស៊ាន (៤,៩%) ។ ធៀបនឹងត្រីមាសទី៤ ២00២ ការនាំចេញរបស់កម្ពុជាទៅ US បានកើនគួរកត់សំគាល់ដល់ ១៦,៥% ។

According to Customs and Excise Department, Cambodia's exports declined by 3.4% to US$ 475.8 million in the fourth quarter 2003, compared to the third quarter, mainly due to drop in garment exports to US (by 1.7%). Despite this, however, the US continues to remain the major market for Cambodia's exports (62.8%), followed by EU (26.3%), and ASEAN (4.9%). Compared to the fourth quarter 2002, however, Cambodia's exports to the US rose significantly by 16.5%.

**Cambodia's Exports by Regions**
(in million US dollars)




Source: Customs and Excise Department

នៅខែមករា ២00៤ កម្ពុជានាំចូលស៊ីម៉ង់ ៨៦.២១៥តោន និងដែក ៣.៣00 តោន ។ ធៀបនឹងកាលពី១ឆ្នាំមុន ស៊ីម៉ង់នាំចូលស្ទុះឡើង ៦៨,៧% ប៉ុន្តែដែកនាំចូលថយចុះបន្តិចអស់ ២,២% ។ គិតជាតំលៃ ស៊ីម៉ង់នាំចូលមានសរុប ៣,៦លានដុល្លារ រីឯ ដែកនាំចូលមាន 0,៧លានដុល្លារ ។

In January 2004, Cambodia imported 86,215 tonnes of cement, and 3,300 tonnes of steel. Compared to one year ago, the import of cement jumped by 68.7%, while the import of steel fell slightly by 2.2%. In terms of value, the import of cement was worth US$ 3.6 million and the import of steel US$ 0.7 million.

**Imports of Cement and Steel**
(in thousand tonnes)




Source: Customs and Excise Department

នៅខែមករា ២00៤ កម្ពុជានាំចូលសាំង ៥.២00តោន និងម៉ាស៊ូត ៤១.000 តោន ។ ធៀបនឹងតួលេខមធ្យមប្រចាំខែ សាំងនាំចូលគឺតិចជាងកំរិតមធ្យម រីឯម៉ាស៊ូតនាំចូលមានច្រើនជាងកំរិតមធ្យម ។ រដ្ឋប្រមូលចំនូលបាន ១,៨លានដុល្លារពីការនាំចូលសាំង និង ៥,៧លានដុល្លារពីការនាំចូលម៉ាស៊ូត ហើយក្នុងនេះ VAT តំណាងឱ្យ ១៧,៤%នៃចំណូលលើសាំង និង ២៦,៦%នៃចំណូលលើម៉ាស៊ូត ។

In January 2004, Cambodia imported 5,200 tonnes of gasoline and 41,000 tonnes of diesel. Compared to monthly average figures, gasoline imports were below average while diesel imports were significantly above average. The government collected US$ 1.8 million as revenues from gasoline imports, and US$ 5.7 million from diesel imports. Of this, VAT on gasoline imports accounted for 17.4% of revenues, and that on diesel imports contributed 26.6% of revenues.

**Imports of Petroleum Products**
(in thousand units)




Source: Customs and Excise Department

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

តាមពតិមានពី CDC, នៅឆ្នាំ២០០២-២០០៤ មានផែនការវិនិយោគ ២១,៦ លានដុល្លារក្នុងការអប់រំកំរិតខ្ពស់ ។ ក្នុងនេះ វិនិយោគលើ វិទ្យាស្ថានបច្ចេកវិទ្យា និងអភិវឌ្ឍន៍គ្រូបង្រៀន មាន ៧៤%, ការអភិវឌ្ឍន៍ការអប់រំកំរិតខ្ពស់ មាន ១៩%, និង ការកែលំអគុណភាពនិងប្រសិទ្ធភាពការអប់រំកំរិតខ្ពស់ មាន ៧% ។ សំរាប់វិនិយោគទាំងនេះ រដ្ឋកម្ពុជាបានប្តេជ្ញាទុនតែ ០,៥លានដុល្លារ ។

According to the CDC, US$ 21.6 million was planned for investment in higher education during 2002-2004. Of this, the share of investment in "Institute of Technology and Teacher Development" was 74% (US$ 15.9 million), followed by the share of "Higher Education Development" and "Improving the Quality and Efficiency of Higher Education" with 19 % and 7%, respectively. For these investments, the Cambodian government has committed just US$ 0.5 million, while the remaining US$ 21.1 million depends on additional funding from partners.

**Planned Investment in Higher Education 2002-2004**




Source: Council for the Development of Cambodia

តាមពតិមាន CDC ជំនួយរបស់ធនាគារពិភពលោកដល់ គំរោងកំពុងដំណើរការនៅឆ្នាំ២០០២-២០០៤ មាន ៣៣លានដុល្លារ ក្នុងនេះ ១៨,៧លានដុល្លារ (៥៦,៦%) បានប្រើក្នុងឆ្នាំ២០០២, ១២លានដុល្លារ (៣៦,៤%) បានប្រើក្នុងឆ្នាំ២០០៣ និង ២,៣លានដុល្លារ (៧%) ទុកប្រើក្នុងឆ្នាំ២០០៤ ។ ទុនភាគច្រើន (១៨,៥លានដុល្លារ ឬ ៥៦%) សំរាប់ធ្វើផ្លូវជាតិលេខ១ ឡើងវិញ ។

According to the CDC, World Bank support for on going projects for the period 2002-2004 was US$ 33 million. Of this, US$ 18.7 million (56.6%) was used in 2002, and US$ 12 million (36.4%) in 2003. The remaining amount (US$ 2.3 million or 7%) has been earmarked for 2004. Most of the money (56% or US$ 18.5 million) was devoted to reconstruction of highway Nr. 1. This figure does not include World Bank joint funding.

**World Bank on going Projects**
2002-2004 (in million US dollars)




Source: Council for the Development of Cambodia

តាមពតិមាន CDC ផែនការវិនិយោគសរុបលើផ្លូវ មាន ១៦៨,៦លានដុល្លារ សំរាប់ឆ្នាំ២០០២-២០០៤ ។ ក្នុងនេះ ៧៤,៧លានដុល្លារ (៤៤%) បានបែងចែកសំរាប់ឆ្នាំ២០០២, ៥៣,៦លានដុល្លារ (៣១,៥%) សំរាប់២០០៣ និង ៤០,៣លានដុល្លារ (២៤,៥%) ទុកសំរាប់២០០៤ ហើយ គំរោង "បណ្តាញដឹកជញ្ជូនជាតិ" ផ្តល់ទុនដោយ ADB មានចំណែកធំបំផុត (២៧,៥% ឬ ១១លានដុល្លារ) ។

According to the CDC, total planned investment in roads was US$ 168.6 million in the period 2002-2004. Of this, US$ 74.7 million (44%) was allocated to 2002, and US$ 53.6 million (31.5%) to 2003. The remaining amount (US$ 40.3 million or 24.5%) was reserved for 2004. Of this, the "National Transport Network" project funded by the ADB claimed the largest share (27.5% or US$ 11 million).

**Planned Investment in Roads 2002-2004 (million US$)**




Source: Council for the Development of Cambodia

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

តាមតួលេខបណ្ដោះអាសន្នពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថវិកាចរន្តរបស់កម្ពុជាមានអតិរេក ៥៧,៦ពាន់លានរៀលនៅត្រីមាសទី៤ ២០០៣ ។ សំរាប់ពេញមួយឆ្នាំ២០០៣ អតិរេកមាន ១៧៧,៤ពាន់លានរៀល ឬ ៨២,៥%នៃផែនការកំណត់ក្នុងច្បាប់ថវិកាឆ្នាំ២០០៣ ប៉ុន្តែវាមានកំរិត ១៦%ខ្ពស់ជាងអតិរេកក្នុងឆ្នាំ២០០២ ដែលកាលនោះសំរេចបានតែ ៧១%នៃផែនការ ។

According to provisional figures from the Ministry of Economy and Finance, Cambodia's current budget had an operational surplus of 57.6 billion riels in the fourth quarter, 2003. For the year as a whole the surplus reached 177.4 billion riels or 82.5% of the target set by the Budget Law 2003. However, this is 16% more than the surplus in 2002 when it was able to achieve only 71% of the target.

**Current Budget Operations**
(commitments-billion riels)




* Q4-03 provisional
Source: Ministry of Economy and Finance

ចំណូលថវិកាចរន្តឡើងដល់ ៥០៦ពាន់លានរៀលនៅត្រីមាសទី៤ ២០០៣ ធៀបនឹង ៣៩៩ពាន់លានរៀលនៅត្រីមាសទី៣ ហើយចំណូលប្រចាំឆ្នាំសរុបឡើងដល់ ១.៦៨២ពាន់លានរៀល ។ ធៀបនឹងផែនការក្នុងច្បាប់ថវិកាឆ្នាំ២០០៣ ការប្រមូលចំណូលចរន្តសំរេចបានត្រឹម ៨៥% ក្នុងនេះចំណូលពន្ធគយបានទាបបំផុតត្រឹម ១៩៧,៦ពាន់លានរៀល ឬ ៧៧%នៃផែនការ ។

Current budget revenues rose to 506 billion riels in the last quarter 2003, up from 399 billion riels in the preceding quarter, with overall annual revenues reaching 1,682 billion riels. Compared to the target set by the Budget Law 2003, current revenue collection achieved just 85% of target. Revenue received from excise duties (197.6 billion riels) was the worst offender, reaching only 77 % of the target. Compared to the previous year, this constitutes a 6 % decline.

**Current Budget Revenues**
(billion riels)




* Q4-03 provisional
Source: Ministry of Economy and Finance

នៅត្រីមាសទី៤ ២០០៣ ចំនាយចរន្តសរុបមាន ៤៤៨ពាន់លានរៀល ហើយសំរាប់ឆ្នាំ២០០៣ ទាំងមូល វាមានចំនួន ១.៥០៤,៥ពាន់លានរៀល ឬត្រឹមតែ ៨៥%នៃផែនការចំណាយប្រចាំឆ្នាំប៉ុណ្ណោះ ។

In the fourth quarter 2003, current expenditures totalled 448 billion riels while for 2003 as a whole, current expenditures reached 1,504.5 billion riels. In other words, annual expenditures were able to reach only 85% of the target set.

**Current Budget Expenditures**
(billion riels)




*Q4-03 provisional
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែមករា ២០០៤ ផលិតកម្មឧស្សាហកម្ម US កើនឡើងតាមអត្រាប្រចាំឆ្នាំ ២,៤% ដែលបណ្តាលជាសំខាន់ដោយកំនើនផលិតកម្មខាង រថយន្ត គ្រឿងម៉ាស៊ីនប្រើក្នុងផ្ទះ សង្ហារឹម កំរាលព្រំ បរិក្ខារអាជីវកម្ម និង គ្រឿងម៉ាស៊ីនផ្សេងទៀត (ABC News) ។ ក្នុងខែដដែល កំណើនផលិតកម្មឧស្សាហកម្មនៅតំបន់អឺរ៉ូ ចុះដល់ ០,៦% ឯនៅជប៉ុនវាកើនយឺតជាងមុនត្រឹម ៤,៩% បើធៀបនឹងខែមករា ២០០៣ ។

Industrial production in the US grew at an annual rate of 2.4% in January 2004. The gains were mainly due to increased production of automotive products, appliances, furniture and carpeting, business equipment and machinery, according to ABC News. At the same time, the growth of industrial production in the Euro area slowed to 0.6% year-on-year basis. Japan's industrial production grew more slowly (by 4.9%) in January 2004, compared to January 2003.

**Industrial Production in the US, Europe and Japan**
(percentage change over the previous year)




Sources: The Economist

នៅខែមករា ២០០៤ ផលិតកម្មឧស្សាហកម្មចិនថយកំណើនយ៉ាងខ្លាំងមកត្រឹម ៧,២% ធៀបនឹង ១៨,១%នៅខែធ្នូ ២០០៣ ប៉ុន្តែវារើបរិញយ៉ាងលឿននៅខែកុម្ភៈ ២០០៤ តាមអត្រាកំណើនប្រចាំឆ្នាំ ២៣,២% ដែលជាអត្រាខ្ពស់បំផុតតាំងពីឆ្នាំ១៩៩៩ ។ នៅខែមករា ២០០៤ ផលិតកម្មឧស្សាហកម្មកូរ៉េខាងត្បូង មានអត្រាកំណើនប្រចាំឆ្នាំថយចុះមកត្រឹម ៤,៨% ។

In January 2004, China's industrial output growth dropped dramatically to 7.2% from 18.1% in December 2003. However it quickly recovered to reach an annual growth rate of 23.2% in February 2004, the fastest pace since 1999. Industrial production in South Korea declined to 4.8% year-on-year basis in January 2004.

**Industrial Production in China and South Korea**
(percentage change over the previous year)




Sources: The Economist

នៅខែមករា ២០០៤ ផលិតកម្មឧស្សាហកម្មនៅម៉ាឡេស៊ីកើន ១៦,៧% (ធៀបនឹងខែដូចគ្នាឆ្នាំមុន) ដែលជំរុញដោយកំណើន ២០,៧%ក្នុងវិស័យកម្មន្តសាល (ពតិមានពីនាយកដ្ឋានស្ថិតម៉ាឡេស៊ី) ។ ក្នុងរយៈពេលដដែល ផលិតកម្មឧស្សាហកម្មនៅថៃថយកំណើនមកត្រឹម ១១,៦% ឯនៅ សិង្ហបូរី វាកើនដល់ ៥,៨% ។

In January 2004, Malaysia's industrial output rose by 16.7% over the same month last year. The rise in industrial output was fuelled by an expansion of 20.7% in the manufacturing sector, according to the Department of Statistics, Malaysia. During the same period, industrial production in Thailand slowed to 11.6%, while industrial production in Singapore rose by 5.8%.

**Industrial Production in Some ASEAN Countries**
(percentage change over the previous year)




Sources: The Economist

*Note: The latest data available is for January 2004.*

# អត្រាអតិផរណានៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា
# Inflation Rates in Selected Economic Partners of Cambodia

នៅមករា ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិក កើន ១,៩% បើធៀបនឹងកាលពី១ឆ្នាំមុន ដោយសារកំណើនថ្លៃថាមពលជាសំខាន់ ។ ក្នុងពេលដដែល ថ្លៃទំនិញប្រើប្រាស់នៅជប៉ុនធ្លាក់អស់ ០,៣% ( តិចជាងកាលពីខែធ្នូ ២០០៣ ដែលធ្លាក់អស់ ០,៤%) ។ ម្យ៉ាងទៀត អត្រាអតិផរណានៅតំបន់អឺរ៉ូកើនដល់ ២% នៅខែមករា ២០០៤ គឺដល់កំរិតអតិបរមាកំណត់ដោយធនាគារកណ្ដាលរបស់អឺរ៉ុប ។

In January 2004, consumer prices in the US rose by 1.9% compared to a year earlier. This was largely due to higher energy prices. At the same time, consumer prices in Japan fell by 0.3%, lower than the 0.4% fall in December 2003. On the other hand, inflation rates in the Euro area rose by 2% in January 2004, hitting the ceiling set by the European Central Bank.

**Inflation Rate in the US, Europe and Japan**
(percentage change over the previous year)




Sources: IMF and the Economist

នៅមករា ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅចិន កើន ៣,២% ធៀបនឹងកាលពី១ឆ្នាំមុន ( អត្រាដូចគ្នានឹងខែធ្នូ) ក្នុងនេះថ្លៃម្ហូបអាហារបន្តកើនឡើង (Channel News Asia) ។ បរិត្តផរណានៅហុងកុងបន្តធូរស្រាល ដោយសារកំណើនតំរូវការប្រើប្រាស់ (INQ7) ។ ថ្លៃទំនិញប្រើប្រាស់នៅហុងកុងធ្លាក់ដល់ ១,៥% ហើយអត្រាអតិផរណានៅកូរ៉េខាងត្បូងឡើងដល់ ៣,៤% បើធៀបនឹងឆ្នាំមុន ។

In January 2004, consumer prices in China rose by 3.2% over a year earlier- the same rate as in December, with food prices continuing to increase, according to Channel News Asia. Deflation in Hong Kong continued to ease further on the back of improving consumer demand, according to INQ7. Consumer prices in Hong Kong fell by 1.5% in January 2004. During the same period, inflation rate in South Korea rose by 3.4% over the previous year.

**Inflation Rate in China, Hong Kong and South Korea**
(percentage change over the previous year)




Sources: IMF and the Economist

នៅមករា ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅម៉ាឡេស៊ីកើន ១% ធៀបនឹងខែដូចគ្នាឆ្នាំមុន ឬ ០,២%ទាបជាងខែមុន ។ ក្នុងពេលដដែល ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបូរីកើន ១,៣% ធៀបនឹងខែមករា ២០០៣ ។ តាមទិន្នន័យរបស់នាយកដ្ឋានស្ថិតិសិង្ហបូរី រឿងនេះឆ្លុះបញ្ចាំងកំណើនថ្លៃម្ហូបអាហារក្នុងពេលចូលឆ្នាំចិន ។ នៅខែមករា ២០០៤ អតិផរណានៅថៃចុះដល់ ១,២% ។

In January 2004, consumer prices in Malaysia rose by 1% over the same month last year, 0.2-percentage point slower than in the preceding month. During the same period, consumer prices in Singapore rose by 1.3% over January 2003. According to the data released by the Department of Statistics, Singapore, this reflects higher food prices during the Lunar New Year.

Inflation rates in Thailand fell to 1.2% in January 2004.

**Inflation Rate in Selected ASEAN Countries**
(percentage change over the previous year)




Sources: IMF and the Economist

*Note: The latest data available is for January 2004.*

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in the World Markets

នៅខែមីនា ២០០៤ ដុល្លារUS ចាប់ផ្តើមឡើងថ្លៃទល់នឹងប្រាក់យ៉េនដោយប្តូរបាន ១១០,៧យ៉េន /ដុល្លារ ឬឡើងថ្លៃ ៣,៧% ធៀបនឹងខែមុន ។ រឿងនេះកើតឡើងជាសំខាន់ដោយសារអន្តរាគមន៍របស់ អាជ្ញាធរជប៉ុនដែលបារម្ភថា រូបិយវត្ថុខ្លាំងអាចប៉ះពាល់ដល់ការរីបសេដ្ឋកិច្ចដែលជំរុញដោយការនាំចេញ ( មតិពាណិជ្ជករ ) ។ ដុល្លារUS ឡើងថ្លៃទល់នឹងប្រាក់អឺរ៉ូផងដែរដោយប្តូរបាន ០,៨១អឺរ៉ូ/ដុល្លារUS នៅខែមីនា ២០០៤ ។

In March 2004, the US dollar began to strengthen against the Japanese yen reaching 110.7 yen/dollar, an appreciation of 3.7% over the previous month. This was largely due to an intervention by Japanese authorities, who feared a stronger currency could jeopardise an export-led economic recovery, dealers said. The US dollar gained its value against the euro as well, trading at 0.81euro/US$ in March 2004.

**Euro and Japanese Yen Against the US Dollar**




*Note: Data is up to 15th, March 2004*
Sources: The Economist and the Fed

នៅខែមីនា ២០០៤ ដុល្លារUS បន្តឡើងថ្លៃ៦ខែជាប់គ្នាទល់នឹងដុល្លារហុង-កុង ដោយប្តូរបាន ៧,៧៩ដុល្លារហុងកុង/ដុល្លារUS ឬ ឡើងថ្លៃ ០,២% ធៀបនឹងខែមុន ។ ដុល្លារUS ក៏ឡើងថ្លៃ ០,៦% ទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូងដែរ ដោយប្តូរបាន ១.១៧៥វ៉ុន/ដុល្លារUS ។ រឿងនេះឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់ដោយសារការចោទប្រកាន់លើប្រធានាធិបតីកូរ៉េ និងកង្វះអន្តរាគមន៍ពីសំណាក់អាជ្ញាធររូបិយវត្ថុ (Business Times) ។

In March 2004, the US dollar continued to appreciate against the Hong Kong dollar for the sixth consecutive month, rising by 0.2% to 7.79 HK dollars/US$ over the previous month. The US dollar also appreciated against the South Korea won by 0.6% to 1,175 won/US$. This reflects the uncertainties introduced by the impeachment of the Korean president and lack of intervention by the monetary authorities, according to the Business Times.

**South Korean Won and Hong Kong Dollar Against the US Dollar**




*Note: Data is up to 15th, March 2004*
Sources: The Economist and the Fed

នៅខែមីនា ២០០៤ ដុល្លារUS ឡើងថ្លៃ ១% ទល់នឹងដុល្លារសឹង្ហបូរីដល់ ១,៧ដុល្លារសឹង្ហបូរី/ដុល្លារUS ប៉ុន្តែគេរំពឹងថាវាចុះថ្លៃវិញដល់ ១,៦៦ដុល្លារសឹង្ហបូរី/ដុល្លារUSជាមធ្យមក្នុងឆ្នាំ២០០៤ទាំងមូល (Business Times) ។ ដុល្លារUS ឡើងថ្លៃទល់នឹងប្រាក់បាតថៃដល់ ៣៩,៤បាត/ ដុល្លារUS ធៀបនឹង ៣៩,១បាត/ដុល្លារUS នៅខែកុម្ភៈ ២០០៤ ។

In March 2004, the US dollar strengthened against the Singapore dollar by 1%, to 1.7 S$/US$. However, the US dollar is expected to weaken against the Singapore dollar to about an average of 1.66 S$/US$ for 2004 as a whole, according to the Business Times. The US dollar appreciated against the Thai baht, rising to 39.4 baht/US$ in March 2004, from 39.1 baht/US$ in February.

**Thai Baht and Singaporean Dollar Against the US Dollar**




*Note: Data is up to 15th, March 2004*
Sources: The Economist and the Fed

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in the World Markets

នៅខែមីនា ២០០៤ ថ្លៃអង្ករលេខ១ នៅផ្សារអន្តរជាតិក្រុងបាងកកឡើងថ្លៃ ដល់ ២២៣ដុល្លារ/តោន ឬកំណើន ៦%ធៀបនឹងខែកុម្ភៈ ។ អង្ករពឹងថានឹងបន្តឡើងថ្លៃក្នុងឆ្នាំ២០០៤ ពីព្រោះចិនដែលតែងនាំចេញអង្ករជាង ២លានតោន/ឆ្នាំ បានចាប់ផ្តើមនាំចូលអង្ករពីវៀតណាម និងថៃ បន្ទាប់ពីបានខូចខាតផលស្រូវមួយចំនួន ។ ក្នុងពេលដដែល ថ្លៃសណ្តែកសៀងស្ទុះឡើង ១៩% ដល់ ២៦១ដុល្លារ/តោន ធៀបនឹង ២១៨ដុល្លារ/តោននៅខែកុម្ភៈ ។

The price of first quality rice in the Bangkok international market increased by 6% to 223 US$/tonne in March 2004, compared to February 2004. The price of rice is expected to continue to rise in 2004, as China-which used to export over 2 million tonnes of rice a year-has started to import rice from Vietnam and Thailand after a series of crop failures, according to VNANET. During the same period, the price of soybeans jumped by 19% to 261 US$/tonne, up from 218 US$/tonne in February 2004.

**Prices of Rice and Soybeans**
(US$/tonne)




*Note: Data is up to 15th, March 2004*
Source: FEER

នៅខែមីនា ២០០៤ ថ្លៃកៅស៊ូនៅផ្សារអន្តរជាតិនៅម៉ាឡេស៊ីកើន ១២,៧% ដល់ ១.៣២៩ដុល្លារ/តោន ធៀបនឹង ១.១៧៩ ដុល្លារ/តោននៅខែមុន។ ថៃ ម៉ាឡេស៊ី និង ឥណ្ឌូនេស៊ី បានបង្កើតមូលនិធិកៅស៊ូបីប្រទេស ដើម្បីទប់ថ្លៃកៅស៊ូឱ្យនៅត្រឹម ១.១០០ដុល្លារ/តោន ។ ប្រេងឆាបន្តឡើងថ្លៃ២ខែជាប់គ្នាដល់ ៥១០,៧ដុល្លារ/តោន ឬកើន ៧,៧%ធៀបនឹងកុម្ភៈ ២០០៤ ។

In March 2004, the price of rubber in the Malaysia International Market rose significantly by 12.7% to 1,329 US$/tonne, up from 1,179 US$/tonne in the previous month. According to the China View, Thailand, Malaysia and Indonesia have set up a three nation rubber fund in an effort to keep world rubber price stable at around 1,100 US$/tonne. At the same time, the price of palm oil continued to increase for the second consecutive month to 510.7 US$/tonne, an increase of 7.7% from February 2004.

**Prices of Rubber and Palm Oil**
(US$/tonne)




*Note: Data is up to 15th, March 2004*
Source: FEER

នៅខែមីនា ២០០៤ ប្រេងឆៅឡើងថ្លៃ ៩,៤% ដល់ ៣០,៤ដុល្លារ/ធុង (២៧,៨ដុល្លារ/ធុងនៅខែមុន) ។ រឿងនេះឆ្លុះបញ្ចាំងពីសេចក្តីសំរេចរបស់ OPEC ក្នុងការកាត់បន្ថយកូតាផលិតកម្មផ្លូវការចំនួន ១លានធុង/ថ្ងៃ ចាប់ពីថ្ងៃទី ១ មេសា ។ សាំងបន្តឡើងថ្លៃដល់ ២៧,៧សេន/លីត្រ នៅខែមីនា ២០០៤ ធៀបនឹង ២៦,៦សេន/លីត្រ នៅខែមុន។

In March 2004, the price of crude oil edged up by 9.4% to 30.4 US$/barrel, up from 27.8US$/barrel in the pervious month. This may reflect the OPEC decision to cut official production quotas by 1 million barrels per day from April 1, according to Reuters. The price of gasoline rose further to 27.7 cents/litre in March 2004, up from 26.6 cents/litre in the previous month

**Prices of Crude Oil and Gasoline**




*Note: Data is up to 15th, March 2004*
Sources: IMF, EIA and IEA